# ប្រទេសកម្ពុជា

## របាយការណ៍ស្តីអំពី  សេរីភាពសាសនាអន្តរជាតិប្រចាំឆ្នាំ២០០៤

## ចេញផ្សាយដោយ ការិយាល័យលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

រដ្ឋធម្មនុញ្ញបានផ្តល់អោយមាននូវសេរីភាពខាងសាសនា ហើយជាទូទៅនៅក្នុងការអនុវត្តន៏ជាក់ស្តែង រដ្ឋាភិបាលគោរពនូវសិទ្ធិសេរីភាពនេះ ។ ទោះជាយ៉ាងនេះក្តី ព្រះពុទ្ធសាសនាគឺជាសាសនារបស់របស់រដ្ឋ ។

ស្ថានភាពនៃការគោរពសេរីភាពខាងសាសនារបស់កម្ពុជា មិនមានការផ្លាស់ប្តូរទេ នៅក្នុងកំលុងពេលគ្របដណ្តប់ក្នុងរបាយការណ៏នេះ ហើយគោលនយោបាយរបស់រដ្ឋាភិបាល នៅតែបន្តអោយមានការអនុវត្តន៏សេរីភាពខាងសាសនានេះ បានយ៉ាងទូលំទូលាយ ។

ទំនាក់ទំនងដោយមេត្រីភាព ជាទូទៅរវាងបណ្តាសាសនាទាំងឡាយនៅក្នុងសង្គម ជាកត្តាចូលរួមជំរុញអោយមានសេរីភាពខាងសាសនា ។

រដ្ឋាភិបាលសហរដ្ឋអាមេរិក ពិភាក្សាបញ្ហាសេរីភាពសាសនាជាមួយនឹងរដ្ឋាភិបាលកម្ពុជា ដោយចាត់ទុកថា វាគឺជាផ្នែកមួយនៃគោលនយោបាយទូទៅ ក្នុងការជំរុញលើកស្ទួយសិទ្ធិមនុស្ស ។

### ផ្នែកទី១:  ប្រជាសាស្ត្រសាសនា

ប្រទេសកម្ពុជាមានទំហំផ្ទៃដីសរុបប្រហែលជា ៦៧000 ម៉ាលស៏ការេ ( ១៣១,0៣៥គីឡូម៉ែត្រការេ) និងមានប្រជាជនប្រមាណ ១៣,៤ លាននាក់ ។ ប្រហែលជា ៩៣ភាគរយនៃប្រជាជនទាំងអស់ គឺជាអ្នកកាន់ពុទ្ធសាសនានិកាយហីនយាន ។ ប្រពៃណីព្រះពុទ្ធសាសនាបានសាយភាយ និងមានសកម្មភាពនៅគ្រប់បណ្តាខេត្តទាំងអស់ ដោយមានវត្តប្រមាណជា៤១០០វត្ត នៅទូទាំងប្រទេស ។ ដោយហេតុថា ជនជាតិខ្មែរភាគច្រើនលើសលប់ គឺជាអ្នកកាន់សាសនាព្រះពុទ្ធ  ព្រះពុទ្ធសាសនា វប្បធម៌ប្រពៃណីខ្មែរ និងជីវិតរស់នៅប្រចាំថ្ងៃ មានទំនាក់ទំនងយ៉ាងជិតស្និតរវាងគ្នានឹងគ្នា ។ ជាទូទៅ ការប្រកាន់ខ្ជាប់នូវព្រះពុទ្ធសាសនា ត្រូវបានគេចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណជាតិសាសន៏ និងវប្បធម៌របស់ប្រទេសកម្ពុជា ។ ប្រជាជនដែលនៅសល់ពីនេះ រួមមានជនជាតិមូស្លីមប្រហែល៧00000នាក់ ដែលភាគច្រើនគឺជាជនជាតិចាម រស់នៅតាមភូមិនេសាទនៅ តាមទីប្រជុំជន និងជនបទនានា នៅតាមដងទន្លេសាប ទន្លេមេគង្គ និងនៅខេត្តកំពត ។ មានជនជាតិចាម៤ សាខា រស់នៅក្នុងប្រទេសកម្ពុជាគឺ: សាខាស្យាហ្វីដែលទទួលឥទ្ធិពលពីពួកម៉ាឡេ មាន

៨៨ភាគរយនៃជនជាតិ ចាមមូស្លីម, សាខាសាឡាហ្វី ដែលទទួលឥទ្ធិពលពីពួកសាអូឌីគូវ៉ាទី (ចួនកាលគេហៅថា វ៉ាហាប៊ី) មាន៦ភាគរយ, សាខាបូរាណ អីម៉ានសាន មាន៣ភាគរយ និងសាខាកាឌីអានី មាន៣ភាគរយដែរនៃប្រជាជនទាំងអស់ ។ សហគមន៍សាសនាគ្រីស្តដ៏តូចរបស់ប្រទេសកម្ពុជា ទោះបីជាកំពុងតែរីកដុះដាលក៏ដោយ ក៏មានចំនួនតែប្រមាណជាជាង ១ភាគរយប៉ុណ្ណោះនៃប្រជាជនសរុប ។ អង្គការ និងនីកាយសាសនាគ្រីស្តចំនួនជាង១០០ ធ្វើសកម្មភាពយ៉ាងមានសេរីភាពនៅក្នុងប្រទេស ដោយរួមបញ្ចូលទាំងសហធម្មចារីចំនួនជាង១០០០ទៀតផង ។ អង្គការសាសនាដទៃទៀត ដែលមានអ្នកគោរពតាមតិចតួចរួមមាន សាសនាការដាយរបស់វៀតណាម និងជំនឿបាហាអី ដែលមានសមាជិកសកម្មប្រមាណជា២០០០នាក់ នៅក្នុងក្រុមនីមួយៗ ។

## ផ្នែកទី២:  ស្ថានភាពនៃសេរីភាពខាងសាសនា

### *ក្របខ័ណ្ឌនយោបាយ និងច្បាប់*

រដ្ឋធម្មនុញ្ញបានផ្តល់អោយមានសេរីភាពខាងសាសនា ហើយជាទូទៅរដ្ឋាភិបាលបានគោរពសិទ្ធិនេះក្នុងការអនុវត្តន៏ ។ ជាទូទៅ រដ្ឋាភិបាលគ្រប់ជាន់ថ្នាក់បានការពារសិទ្ធិនេះបានយ៉ាងពេញលេញ ហើយមិនយោគយល់ដល់ការរំលោភបំពានលើសិទ្ធិនេះ ពីសំណាក់អាជ្ញាធរ ឬបុគ្គលឯកជនឡើយ ។ ព្រះពុទ្ធសាសានាជាសាសនារបស់រដ្ឋ ។ រដ្ឋាភិបាលលើកតំកើងដល់ថ្ងៃបុណ្យព្រះពុទ្ធសាសនារបស់ជាតិ និងបានផ្តល់នូវការអប់រំ និងបណ្តុះបណ្តាលវិស័យព្រះពុទ្ធសាសនា ដល់ព្រះសង្ឃ និងអ្នកដទៃទៀតនៅក្នុងវត្តអារាមនានា ព្រមទាំងបានផ្តល់នូវការគាំទ្រយ៉ាងសមរម្យ ដល់វិទ្យាស្ថានមួយដែលធ្វើការស្រាវជ្រាវ និងបោះពុម្ពផ្សាយសៀវភៅដែលទាក់ទងនឹងវប្បធម៌ខ្មែរ និងប្រពៃណីទំនៀមទំលាប់ព្រះពុទ្ធសាសនា ។

ច្បាប់រដ្ឋបានតំរូវអោយក្រុមអ្នកកាន់សាសនាទាំងអស់ រួមទាំងពុទ្ធសាសនិកជនផងដែរ ដាក់ពាក្យសុំទៅក្រសួងធម្មការនិងកិច្ចការសាសនា ដើម្បីកសាងទីកន្លែងសក្ការៈ និងសំរាប់ធ្វើសកម្មភាពសាសនាផ្សេងៗ ។ ក្នុងសំណុំលិខិតទាំងនោះ ក្រុមអ្នកកាន់សាសនាត្រូវតែបញ្ជាក់អោយបានច្បាស់លាស់ អំពីគោលបំណង និងសកម្មភាពសាសនារបស់គេ ដែលត្រូវតែគោរពទៅតាមច្បាប់ ដែលបានហាមឃាត់មិនអោយធ្វើការប្រមាថសាសនាដទៃ បង្កទំនាស់ រឺធ្វើអោយប៉ះពាល់ដល់សន្តិសុខជាតិឡើយ ។ មិនមានការដាក់ទោសទណ្ឌ ដល់ការខកខានក្នុងការសុំចុះបញ្ជីឡើយ ។ ក្រុមសាសនាទាំងឡាយ មិនមានការលំបាកច្រើនក្នុងការ

សុំការអនុញ្ញាតិសាងសង់ទីកន្លែងធ្វើសក្ការបូជាទេ ។ នៅក្នុងកំលុងពេលគ្របដណ្តប់ក្នុងរបាយការណ៍នេះ មិនមានការរាយការណ៍អំពីការហាមឃាត់ធំដុំណាមួយ ទៅលើការជួបប្រជុំសាសនាឡើយ ។

ក្នុងខែមករា ឆ្នាំ២០០៣ ក្រសួងធម្មការ និងកិច្ចការសាសនា បានចេញសេចក្តីណែនាំមួយស្តីពីការត្រួតពិនិត្យលើសាសនាដែលមកពីក្រៅប្រទេស ។ សេចក្តីណែនាំនោះ តំរូវអោយមានការចុះបញ្ជី អំពីទីកន្លែងធ្វើសក្ការបូជា និងសាលាបង្រៀនសាសនានានា បន្ថែមទៅលើការអនុញ្ញាតិរបស់រដ្ឋាភិបាល មុនពេលសាងសង់ទីកន្លែងសក្ការបូជាថ្មីណាមួយ ។ ទីកន្លែងសក្ការបូជានីមួយៗ ត្រូវស្ថិតនៅឃ្លាតឆ្ងាយពីគ្នាយ៉ាងតិចណាស់ចំងាយ ២គីឡូម៉ែត្រ ហើយមិនត្រូវប្រើប្រាស់សំរាប់បំរើនយោបាយ រឺជាជំរកឧក្រិដ្ឋជន រឺអ្នករត់គេចពីច្បាប់ឡើយ ។ សេចក្តីបង្គាប់នោះបានតំរូវអោយការបង្រៀនផ្នែកសាសនាទាំងឡាយ ត្រូវគោរពដល់សាសនាដទៃទៀត ។ ការកំនត់គំលាតចំងាយដែលបានរៀបរាប់នៅក្នុងសេចក្តីណែនាំនោះ ត្រូវបានគេចាប់ផ្តើមអនុវត្តហើយ ប៉ុន្តែវាកំនត់តែលើការអនុញ្ញាតិសំរាប់សាងសង់ទីសក្ការបូជាថ្មីប៉ុណ្ណោះ វាមិនប៉ះពាល់ដល់ការិយាល័យរបស់អង្គការសាសនាឡើយ ។

មន្ត្រីរដ្ឋាភិបាលនៅតែបន្តរៀបចំការប្រជុំប្រចាំឆ្នាំ ដើម្បីអោយតំនាងនៃក្រុមសាសនាទាំងអស់ ជួបពិភាក្សាគ្នាអំពីការរីកចំរើនផ្នែកសាសនា និងដោះស្រាយបញ្ហាដែលជាកង្វល់ផ្សេងៗ ។ ក្រសួងធម្មការ និងកិច្ចការសាសនា មានតួនាទីចូលរួមជាអាជ្ញាកណ្តាល ក្នុងការដោះស្រាយជំលោះសាសនាមួយចំនួនដែលកើតមានឡើង ។

***ការកំហិតលើសេរីភាពខាងសាសនា***

គោលនយោបាយ និងការអនុវត្តន៏របស់រដ្ឋាភិបាល ជាកត្តារួមចំនែកក្នុងការអនុវត្តន៏យ៉ាងទូលំទូលាយនិងសេរី នូវសេរីភាពសាសនា ។ ជាទូទៅ ក្រុមសាសនទូតបរទេស បានធ្វើសកម្មភាពដោយសេរីក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនមានពើបប្រទះនឹងការលំបាកធំដុំទេ ក្នុងការបំពេញកិច្ចការរបស់ពួកគេ ។ មន្ត្រីរដ្ឋាភិបាលបានសំដែងអំណរគុណដល់កិច្ចការរបស់ក្រុមសាសនាបរទេសនានា ដែលបានផ្តល់ជាជំនួយចាំបាច់មួយចំនួនដល់វិស័យអប់រំ ការអភិវឌ្ឍន៏ជនបទ និងការបណ្តុះបណ្តាលផ្សេងៗ ។ ទោះបីជាយ៉ាងនេះក្តីមន្ត្រីរដ្ឋាភិបាលក៏នៅមានការ ព្រួយបារម្ភខ្លះដែរ ចំពោះក្រុមបរទេសមួយចំនួន ដែលប្រើប្រាស់សំបករូបភាពជាសាសនា ក្នុងការទាក់ទិននឹងកិច្ចការមិនស្របច្បាប់ រឺនយោបាយទៅវិញ ។

សេចក្តីណែនាំនៅឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យសាសនាពីក្រៅប្រទេស បានហាមឃាត់ដល់ការបញ្ចុះបញ្ចូលអោយលះបង់ពីសាសនាមួយទៅសាសនាមួយទៀតជាសាធារណៈ ។ ក៏ប៉ុន្តែ ការអនុវត្តន៏សេចក្តី

ណែនាំនេះ ត្រូវបានកាត់បន្ថយមកនៅត្រឹមតែជាការហាមឃាត់ លើការបញ្ចុះបញ្ចូលអោយផ្លាស់ប្តូរសាសនា ដោយការគោះទ្វារផ្ទះ នៅចន្លោះពេលបាយថ្ងៃត្រង់ពីម៉ោង ១២ ទៅម៉ោង២ តែប៉ុណ្ណោះ ។

មិនមានរបាយការណ៍ស្តីការឃុំឃាំង រឺអ្នកទោសខាងសាសានាឡើយ ។

***ការបង្ខំអោយផ្លាស់ប្តូរសាសនា***

មិនមានរបាយការណ៍ស្តីពីការបង្ខំអោយផ្លាស់ប្តូរសាសនាទេ រួមបញ្ចូលទាំងពលរដ្ឋអាមេរិកមិនទាន់គ្រប់អាយុដែលត្រូវបានគេចាប់ពង្រត់ រឺនាំចេញដោយមិនស្របច្បាប់ចេញពីសហរដ្ឋអាមេរិក រឺក៏របាយការណ៍បដិសេធមិនអនុញ្ញាតអោយពលរដ្ឋទាំងនោះត្រលប់ទៅសហរដ្ឋអាមេរិកវិញផងដែរ ។

***ការរំលោភបំពានពីសំនាក់អង្គការភេរវកម្ម***

មិនមានការរាយការណ៍អំពីការរំលោភបំពាន ដែលសំដៅលើក្រុមសាសនាណាមួយពីសំណាក់អង្គការភេរវកម្ម នៅក្នុងកំលុងពេលគ្របដណ្តប់ក្នុងរបាយការណ៍នេះទេ ។

## ផ្នែកទី៣: អាកប្បកិរិយាសង្គម

ទំនាក់ទំនងដោយមេត្រីភាពជាទូទៅរវាងបណ្តាសាសនាទាំងឡាយនៅក្នុងសង្គមជាកត្តាចូលរួមជំរុញអោយមានសេរីភាពខាងសាសនា ។

នៅក្នុងកំលុងពេលគ្របដណ្តប់ក្នុងរបាយការណ៍នេះ សាសនាតូចៗបានទទួលរងនូវការរើសអើងតែបន្តិចបន្តួច រឺក៏គ្មានទាល់តែសោះ ។ ក៏ប៉ុន្តែ អ្នកកាន់សាសនាអ៊ិស្លាមនិងគ្រីស្ត បានរាយការណ៍អំពីជំលោះតូចតាចមួយចំនួន ។ នៅខែកក្កដា ឆ្នាំ២០០៣ អ្នកភូមិមួយក្រុមដែលមានការខឹងសម្បារ បាននាំគ្នាបំផ្លាញព្រះវិហារសាសនាគ្រីស្តមួយនៅក្នុងខេត្តស្វាយរៀងយ៉ាងធ្ងន់ធ្ងរ ដោយបន្ទោសថា ការសាងសង់ព្រះវិហារនោះកាលពីប៉ុន្មានឆ្នាំមុន បានធ្វើអោយតំបន់នោះជួបប្រទះនឹងគ្រោះរាំងស្ងួត ។ អាជ្ញាធរប៉ូលីស បានទៅកាន់ទីកន្លែងនោះ ដើម្បីទប់ស្កាត់ការវាយប្រហារបន្ថែមទៀតទៅលើព្រះវិហារនោះ ។ នៅខែសីហា ឆ្នាំ២០០៣ កុលសម្ព័ន្ធមួយក្រុមនៅខេត្តរតនគីរី បានទាមទារអោយក្រុមសាសនាគ្រីស្តមួយក្រុម បញ្ឈប់សកម្មភាពបញ្ចុះបញ្ចូលអោយផ្លាស់ប្តូរសាសនានៅក្នុងភូមិរបស់គេ ។

ស្ថានការណ៍តានតឹងម្តងម្កាល ត្រូវបានគេរាយការណ៍ក្នុងចំណោមសាខាផ្សេងៗនៃសាសនាអ៊ិស្លាម ដែលបានទទួលការគាំទ្ររូបិយវត្ថុពីក្រុមនានានៅប្រទេសអារ៉ាប៊ីសាអូឌី គូវ៉េត ម៉ាឡេស៊ី រឺឥណ្ឌូនេស៊ី អាស្រ័យទៅតាមគោលលទ្ធិនៃសាខានីមួយៗ ។ ពុទ្ធសាសនិកជនមួយចំនួន ក៏បានសំដែងការព្រួយបារម្ភផងដែរ ចំពោះ

សហគមន៍ចាមមូស្លីម ដែលបានទទួលជំនួយឧបត្ថម្ភហិរញ្ញវត្ថុពីបរទេស ។ ទោះជាយ៉ាងនេះក្តី ជាទូទៅ ជនជាតិចាមមូស្លីម បានបញ្ចូលខ្លួនទៅក្នុងសង្គមបានយ៉ាងល្អ ព្រមទាំងបានទទួលតំនែងសំខាន់ៗនៅក្នុងផ្នែកពាណិជកម្ម និងក្នុងរដ្ឋាភិបាល ហើយនិងមិនបានប្រឈមមុខនឹងការរើសអើង រឺរំលោភបំពានណាមួយនៅក្នុងកំលុងពេលគ្របដណ្តប់ក្នុងរបាយការណ៍នេះឡើយ ។

មានអង្គការសាសនាគ្រីស្តនិងអន្តរសាសនាមួយចំនួន ដែលជារឿយៗបានទទួលថវិកាគាំទ្រពីសាធារណជនបរទេស ឬបណ្តាក្រុមឯកជនផ្សេងៗ ។

## ផ្នែកទី៤: គោលនយោបាយនៃរដ្ឋាភិបាលសហរដ្ឋអាមេរិក

រដ្ឋាភិបាលសហរដ្ឋអាមេរិក ពិភាក្សាបញ្ហាសេរីភាពសាសនាជាមួយនឹងរដ្ឋាភិបាលកម្ពុជា ដោយចាត់ទុកថា វាជាផ្នែកមួយនៃគោលនយោបាយទូទៅ ក្នុងការជំរុញលើកស្ទួយសិទ្ធិមនុស្ស ។ តំណាងស្ថានទូតអាមេរិក បានជួបជាមួយថ្នាក់ដឹកនាំសាសនាលើបញ្ហាមួយចំនួន និងធ្វើការទាក់ទងជាមួយនឹងតំណាងអង្គការសាសនាក្រៅរដ្ឋាភិបាលនានា ព្រមទាំងក្រុមផ្សេងៗទៀតដែលតំណាងអោយជំនឿព្រះពុទ្ធសាសនា សាសនាអ៊ិស្លាម និងគ្រីស្តសាសនា។ ស្ថានបេសកកម្មបានផ្តួចផ្តើមកម្មវិធីចុះជួបសំណេះសំណាលតាមសហគមន៍ជាមួយនឹងជនជាតិមូស្លីម ដែលកម្មវិធីនេះ បានផ្តល់អោយមានប្រភពពតិមានបន្ថែមទៀត ស្តីអំពីស្ថានភាពសេរីភាពសាសនានៅក្នុងប្រទេសកម្ពុជា សំរាប់ជនជាតិមូស្លីម ។ ជាងនេះទៅទៀត ស្ថានបេសកកម្មនៅបានតាមឃ្លាំមើលយ៉ាងជិតដិត អំពីស្ថានភាពរបស់ប្រជាជនកម្ពុជា និងជនបរទេសដែលជាអ្នកកាន់ជំនឿហ្វាលុងហ្កុងផងដែរ ។

**ចេញផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤**